# សុន្ទរកថារបស់**លោក តាខ៉ាម៉ូរ៉ា ហ៊ីរ៉ូស៊ី** ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២០ កុម្ភៈ ២០១២

**សូមគោរព លោកបណ្ឌិត សាម អ៊ីន នាយកប្រតិបត្តិអង្គការជីវិតថ្លៃថ្នូរ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំ នសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយអង្គការជីវិតថ្លៃថ្នូរ សម្រាប់គម្រោងសាងសង់សាលាបឋមសិក្សាអាញ្ញាសេះ និងសាលាបឋមសិក្សាពាម។

ការអប់រំ និងការអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់វិស័យទាំងនេះដោយចាត់ទុកជាមុំមួយនៃយុទ្ធសាស្ត្រចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិ។ ដោយទទួលស្គាល់ពីសារៈសំខាន់របស់វា រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភដល់វិស័យអប់រំទាំងផ្នែកសម្ភារៈ និងបច្ចេកទេស។

ជំនួយឧបត្ថម្ភដែលផ្តល់ជូនអង្គការជីវិតថ្លៃថ្នូរនាថ្ងៃនេះ គឺដើម្បីសាងសង់អគារសិក្សាថ្មី ២ ខ្នងធ្វើអំពីបេតុងដែលមួយខ្នងមាន៤បន្ទប់ និងមួយខ្នងទៀតមាន៥បន្ទប់ រួមទាំងការកែលម្អបរិក្ខារអនាម័យនៅសាលាបឋមសិក្សាអាញ្ញាសេះ និង សាលាបឋមសិក្សាពាមក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ បញ្ហាមួយដែលខ្ញុំបានលឺនោះគឺថាក្មួយៗសិស្សានុសិស្សនៃសាលាទាំងពីរមានការលំបាកក្នុងការសិក្សានៅក្នុងថ្នាក់នៃអគារសិក្សាដែលធ្វើអំពីឈើ និងចាស់ទ្រុឌទ្រោម។ តាមរយៈគម្រោងនេះ កុមារាកុមារីប្រមាណ៤០០នាក់ ដែលនៅតំបន់ដាច់ស្រយាល នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំកាន់តែប្រសើរ។

ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងជួយលើកទឹកចិត្តសិស្សានុសិស្សក្នុង សាលាបឋមសិក្សាអាញ្ញាសេះ និងសាលាបឋមសិក្សាពាម ឲ្យខំសិក្សាដើម្បីខ្លួនពួកគេផ្ទាល់ក៏ដូចជាដើម្បីការអភិវឌ្ឍន៍ប្រទេសកំណើតរបស់ពួកគេ។ ខ្ញុំក៏សង្ឃឹមផងដែរថា សិស្សានុសិស្សនៅក្នុងសាលានឹងថែរក្សាសាលារៀនឲ្យបានស្អាត និងត្រឹមត្រូវសម្រាប់ពួកគេផ្ទាល់ក៏ដូចជាសម្រាប់កុមារដែលនឹងត្រូវសិក្សានៅសាលាទាំងពីរនេះនាពេលអនាគត។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!